# អ្នកឧកញ៉ា សុត្តន្តប្រីជាឥន្ទ

# Oknha Suttanta Prijà IN




## ១៩២៤ - ១៩៩៤

ឆ្លងខួបទី៧០បន្ទាប់ពីថ្ងៃមរណភាពរបស់លោក

120
KON/1

www.elibraryofcambodia.org

www.elibraryofcambodia.org

ID4845
4845
LE
920
KON/11

# អ្នកឧញ៉ាសុត្តន្ត ប្រីជាឥន្ទ

( ១៩២៤ - ១៩៩៤ )

## ឧទ្ទិសដល់បុណ្យខួបទី ៧០ បន្ទាប់ពីថ្ងៃ មរណភាពរបស់លោក

ការផ្សាយរបស់
នាយកដ្ឋានបោះពុម្ពផ្សាយវប្បធម៌
នៃក្រសួងវប្បធម៌និង វិចិត្រសិល្បៈ

- ឆ្នាំ ១៩៩៤ -

ព្រះរាជាណាចក្រកម្ពុជា
3684/06
3/5
បណ្ណាល័យជាតិ

www.elibraryofcambodia.org

www.elibraryofcambodia.org

# អារម្ភកថា

ប្រទេសជាតិបានឆ្លងកាត់ច្រើនជំនាន់មកហើយ ក្រោមការកត់ត្រាទុករបស់អ្នកប្រវត្តិសាស្ត្រ និងអ្នកនិពន្ធផ្សេងៗ ។

យើងបានដឹងពី រសជាតិនៃរបបគ្រប់គ្រងសង្គម និងសិល្បៈវប្បធម៌ប្រពៃណី របស់ប្រជាជនជំនាន់នោះៗ ដោយសារការការចងចាំនិងកត់ត្រាទុករបស់អ្នកប្រវត្តិសាស្ត្រ និងអ្នកនិពន្ធជំនាន់នោះឯង ។

អ្នក **ឧកញ៉ាសុត្តន្តប្រីជាឥន្ទ** គឺជាអ្នកនិពន្ធម្នាក់ក្នុងចំណោមអ្នកនិពន្ធខ្មែរជាច្រើនទៀត ដែលបានបូជាកម្លាំងកាយ និងគំនិតប្រាជ្ញា ដើម្បីធ្វើឱ្យប្រជាជនខ្មែរជំនាន់នេះ និងជំនាន់ក្រោយ ៗ ទៀតបានយល់ដឹងពីអ្វីៗដែលកន្លងមកហើយ ។

គឺជាការពុះពារ ក្រាញននៀលមួយដ៏អស្ចារ្យ ដែលលោកបានយកចុងប៉ាកា ប្រយុទ្ធតស៊ូជាមួយសម្ពាធសង្គមនាសម័យនោះ ។ អ្វីដែលជនសម័យនោះចាត់ទុកថា ជាការប្បូរចេញពីមនោសញ្ចេតនាធម្មតា ឬថាជាការត្រិះរិះពិចារណាដ៏សែនរវើរវាយ ពេលនេះដំណក់ញើស និងដំណក់ទឹកខ្មៅទាំងនោះ បានក្លាយមកជាការត្រួសត្រាយផ្លូវមួយសំរាប់អ្នកអក្សរសាស្ត្រ និងអក្សរសិល្ប៍គ្រប់ប្រភេទ សិក្សាស្រាវជ្រាវ ស្វែងយល់ និងជាកូនសោរដ៏ពិសិដ្ឋចាក់ទៅរកពិភពគតិបណ្ឌិតមួយ ។

អ្នក **ឧកញ៉ាសុត្តន្តប្រីជាឥន្ទ** បានត្រូវអ្នកអានខ្មែរក្នុងសតវត្សទី ២០ ចាត់ទុកថាជាអ្នកផ្តួចផ្តើម គំនិតមុនគេបំផុត ដោយបាននិពន្ធរឿងមួយ ១ ដែលបង្កប់ដោយអត្ថន័យ កសាងមនុស្ស កសាងសង្គម និងជាការខិតទៅជិតរបៀបរិះគន់មួយដ៏សុភាពរាបសារចំពោះជីវភាពជាទូទៅក្នុងសម័យ អាណានិគម ។

គេបានឃើញខ្លឹមសារនៃគំនិតរបស់លោកនៅតាមបណ្តាវណ្ណកម្មទាំងឡាយ ដែលជាប់ទាក់ទងទៅនឹងការនិទានផ្សេងៗតាមរយៈកម្រងរឿងគតិលោក ដែលជារឿងសាមញ្ញនិងជាក់ស្តែងបំផុត សំរាប់មនុស្សទូទៅ ។

www.elibraryofcambodia.org

និទានកថាបណ្ឌិតដ៏ក្រអូមក្រអៅ នៃរឿងនិទានទាំងនោះ បានចាក់ឫសជ្រៅក្នុងបេះដូងកូនខ្មែរគ្រប់រូប ទោះបីជារូបលោកបានទទួលមរណៈភាពចំនួន ៧០ ឆ្នាំទៅហើយក្តី ក៏ពាក្យសម្តីនិងផ្នត់គំនិតរបស់លោក នៅរស់រវើកជានិច្ច ហើយនិងរស់រវើកតទៅមុខទៀតជាអមតៈ ។

ដូចនេះបើយើងនិយាយថាក្នុងរយៈពេលដែលលោករស់នៅ អ្នក**ឧកញ៉ាសុត្តន្តប្រីជាឥន្ទ** បានកសាងនូវស្នាដៃដែលជាកុសលជាច្រើន ជាគុណប្រយោជន៍ដល់សង្គមខ្មែរជំនាន់ក្រោយ ដែលយើងជាកុលបុត្រ-កុលធីតាខ្មែរជំនាន់នេះ ត្រូវតែរំលើកនឹកឃើញ ត្រូវតែបូជាគោរព ត្រូវតែដឹងគុណជានិច្ច ។

សូមអោយវិញ្ញាណក្ខ័ន្ធរបស់លោក បានទៅសោយសុខនៅសុគតិភព និងសូមឱ្យស្នាដៃទាំងឡាយរបស់លោក បានឋិតនៅជាកេរមតិកដ៏មានតម្លៃក្នុងជឿនវប្បធម៌អក្សរសាស្ត្រជាតិខ្មែរ ជានិច្ចនិរន្តរ៍ ។

ថ្ងៃ ២៨ វិច្ឆិកា ១៩៩៤

ប្រធានសមាគមអ្នកនិពន្ធកម្ពុជា

**គង់ . ប៊ុនឈឿន**



www.elibraryofcambodia.org

# ជីវប្រវត្តិ នៃឧកញ៉ា សុត្តន្តប្រីជាឥន្ទ

លោក **ឧកញ៉ា សុត្តន្តប្រីជាឥន្ទ** បានកំណើតនៅកោះកែង ស្រុកមុខកំពូល ខេត្តកណ្ដាល នៅ ឆ្នាំ ១៨៥៩ ។ នៅអាយុ ១៥ ឆ្នាំ លោកបានទៅរស់នៅឯខេត្តបាត់ដំបងដោយបានស្នាក់រៀនសូត្រជាមួយព្រះគ្រូ អាចារ្យ សុម នៅវត្តកែវ រហូតដល់អាយុ ២០ ឆ្នាំ ហើយបួសជាភិក្ខុ ។ នៅឆ្នាំបន្ទាប់ លោក ក៏បានទៅបន្តការសិក្សានៅក្រុងបាងកក អស់ពេល ៧ ឆ្នាំ ហើយវិលត្រឡប់មកបាត់ដំបងវិញ ។ លោកមក គង់នៅវត្តកណ្ដាលបាន ១០ ឆ្នាំ ហើយលាចាកសិក្ខាបទ កសាងគ្រួសារនៅភូមិថ្កាធំ ។

លោកបានធ្វើស្នាដៃខ្លួនផ្ទាល់ខាងកំណាព្យកាព្យឃ្លោង និង បានប្រែអត្ថបទ បាលី ជាភាសាខ្មែរ សរុបបានរហូតដល់ ៤៤ ក្បួន ។

នៅគ្រាដែលសៀមត្រួតត្រាខេត្តបាត់ដំបង លោក កថាថន ឈុំ ជាចៅហ្វាយខេត្ត បានតែងតាំងលោក ជា ហ្លួងវិចិត្រវោហារ ជាទីប្រឹក្សាកិច្ចការផ្សេងៗ ក្នុងខេត្ត ។

ក្រោយដែលសៀមបានប្រគល់ខេត្តបាត់ដំបងមកឱ្យខ្មែរវិញនៅឆ្នាំ ១៩០៧ លោកបានមក ធ្វើការនៅភ្នំពេញអស់ពេល ១០ ឆ្នាំ គឺពីឆ្នាំ ១៩១៤ ដល់ឆ្នាំ ១៩២៤ ដោយមានឋានៈជា **ឧកញ៉ា សុត្តន្តប្រីជាឥន្ទ** ។

លុះដល់អាយុ ៦៥ ឆ្នាំ លោក **ឧកញ៉ា សុត្តន្តប្រីជាឥន្ទ** បានវិលទៅខេត្តបាត់ដំបងវិញ។ លោកបានឈឺ ហើយធ្វើមរណកាលនៅឆ្នាំ ១៩២៤ ។



www.elibraryofcambodia.org

## Biography of Oknha Suttanta Prija In

Oknha Suthanta Prija In was born in Rokakong district of Muk Kampoul , Province of Kandal in 1859 .

At nineteen years of age , he went to live in Battambang Province , where he studied with Preah Krou Achar Sok at Wat Keo . when he was twenty years old he became Phikhu and went the following year to Bangkok to continue his study for seven years . And when he returned to Battambang , he remained for ten years at Wat Kandal and then he resigned from the monkhood and married in Chhvea Thom village .

He write and translated forty four texts from Pali .

When Battambang was under Siamese control , The governor , Kothathân Chhum appointed him Hluong Vichit Vohar , a conseler with many studies

After the retrocession of Battambang to Cambodia in 1907 , he went to work in Phnom Penh for ten years , from 1914 to 1924 with the title of Oknha Suttanta Prija In .

At Sixty five years of age , he returned to Battambang, he took ill and died in 1924 .



www.elibraryofcambodia.org

# Biographie de Oknha Suttanta Prija In

Oknha Suttanta Prija In était né à Roka Kong, district de Mouk Kampoul, province de Kandal en 1859.

A l'âge de 19 ans, il allait vivre à Battambong où il étudiait avec Preah Krou Achar Sok à Wath Kèo. Il entra dans le froc à l'âge de 20 ans, et l'année suivante, allait à Bangkok pour continuer ses études pendant sept ans et puis retournait à Battambang. Il s'installait 10 ans à Wath Kandal puis se défroqua et se mariait au village de Chhvea Thom.

Il était un très fameux poète. Il avait écrit et traduit du Pali 44 textes en Khmer.

Au moment où la province de Battambang restait sous la domination siamoise, le gouverneur Kathathân Chhum lui nommait comme son conseiller avec le titre de Luong Vichet Vohar.

Après la retrocession de Battambang au Cambodge en 1907. Il allait travailler à Phnom Penh avec le titre de Oknha Suttanta Prija In pour une période de 10 ans de 1914 à 1924.

Il retournait à Battambang à l'âge de 65 ans. Il tombait malade et mourut en 1924.



www.elibraryofcambodia.org

# ជីវភាពនៃលោកអ្នកឧកញ៉ា
# សុត្តន្តប្រីជាឥន្ទ

លោកអ្នក **ឧកញ៉ា សុត្តន្តប្រីជាឥន្ទ** មហាកវី ពិតជាកវីចេះដឹងជ្រៅជ្រះ ខ្មែរ-សៀម-បាលី មានស្នាដៃល្បីរន្ទឺអស្ចារ្យ ។ លោកមានកំណើតនៅមុខកំពូល ក្រោយមកទៅបួសមិត្តមានគ្រួសារនៅបាត់ដំបង ដោយប៉ិនប្រាជ្ញារៀនសូត្រកត់ត្រា អក្សរសាស្ត្រខ្មែរ ។ លោកមកភ្នំពេញនៅដើមសតវត្សទី ២០ ប្រាកដ រៀបរៀងបកប្រែគម្ពីរសំរាយកំណាព្យហូរហែមុកឱ្យកូនខ្មែរស្រាវជ្រាវសិក្សា ។

យើងសូមគោរព ជូនកិត្តិយសឧត្តមខ្ពង់ខ្ពស់លោកអ្នក **ឧកញ៉ា** ដែលមានស្នាដៃក្រាស់ក្រៃថ្លៃថ្លា ដោយខំរក្សាសួយវប្បធម៌ជាតិ ។

**គួច ឈួន**



www.elibraryofcambodia.org

# ស្នាដៃ នៃ ឧកញ៉ាសុត្តន្ត ប្រីជាឥន្ទ

- គតិលោក « ១០ ខ្សែ »
- និរាសនគរវត្ត
- ចំបាំងតាកែ ភ្នំក្រវាញ
- រឿងអំបែងបែក
- បឋមសម្ពោធ
- លោកនីតិបករណ៍
- សុភាសិត ច្បាប់ស្រី
- ខ្លួនមេកាព្យ ។ ល ។

ពីឆ្នាំ ១៩០១ ដល់ ១៩០៤ លោកបេសកជនសង្ឃកាតូលិក នាម តង់ ដារ នៅបាត់ដំបង ពីឆ្នាំ ១៩០១ ដល់ ១៩០៤ តែងបានប្រឹក្សារៀងរហូតជាមួយ **ឧកញ៉ាសុត្តន្តប្រីជាឥន្ទ** ដើម្បីចងក្រងវចនានុក្រម ខ្មែរ-បារាំង មួយ ដែលគេតែងនិយាយហៅថា វ ច នា នុ ក្រ ម តង់ ដារ ។



www.elibraryofcambodia.org

# Œuvres de Oknha Suttanta Prija In

- Gati lok ( 10 volumes )
- Nireas Nokor Wat
- Chambang Ta kè Phom Kravanh
- Ambèng Bèk
- Patham Sampoth
- Lokanité Pakar
- Supheaset Chbab Srey
- Khuon Mé Kab etc .....

Un missionnaire Catholique nommé Tandart assigné à Battambang de 1901 à 1904 était regulièrement en discussion avec Oknha Suttanta Prijà In pour la rédaction du dictionaire Khmer - Français connu sous le nom de Dictionnaire Tandart.



www.elibraryofcambodia.org

## Works of Oknha Suttanta Prija In

- Gati Lok ( 10 Volumes )
- Nireas Nokor Wat
- Chambaing Takè at Phnom Kravanh
- Ambèng Bèk
- Pathama Samphot
- Lokanite Pakâ
- Supheaset Chbab Srey
- Rule of poetry

A cattolic missionery priest, TANDART assigned to Battambang from 1901 to 1904 went to talk regularly and studied with Oknha Suttanta Prija In for the writing of Khmer - French Dictionary entitled Tandart Dictionary.



www.elibraryofcambodia.org

# កំណាព្យ « ដកស្រង់ពីសៀវភៅ និរាស នគរវត្ត

គន់ត្រីក្បាលទោផ្ទុះដោយក្រៃ　　ខ្លះល្បួតលៃរយ៉ាតង់ប្រុង់ផ្លែផ្កា
សត្វមេជាតិហើរចាប់ចុងសាខា　　ទឹកផលាសត្វពីរ៉ងរនេកក្រៃ ។
ភមរីហើរត្រង់កន្លង់ក៏ចរ　　ត្រីបកេសរបុប្ផាពនាល័យ
សត្វពីង ១ ប្រកីងកណ្ដុកក្រៃ　　ច្រឡំសត្វវេរៃបន្លឺសៀង ។
តែមេត្រូវណោះសត្វតោកវិវេកចិត្ត　　ចំប្រចិកតារិកាជាតួគៀង
កោកិលោ « ១ » លោតលេងបំរះវៀង　　បញ្ចេញសៀងភ្លាំងក្រាំងក្រវៅ « ២ » ។
គន់ចំបក់ដូចបងចំបែងចិត្ត　　ចៅដើមខ្វិតដូចបងមកខ្វែងនៅ
ឱដើមសោកដូចបងបកសោកសៅ　　ដើមស្រឡៅនៅស្រឡាញ់ពេញចោមរោក ។
ឱដើមផ្កាន់គេធ្លាប់ពាក់បដិពៅ　　ដើមស្រឡៅធ្វើចែវគួរកាប់យក
ធ្លកអើយធ្លកមិនធ្លាក់ផ្លែចុះមក　　ខ្ញុំនឹងយកធ្វើប៉ុយបង្ហុយពោះ ។
គន់ដើមពោងរាងហោរហោតដោយខ្យល់　　គេកាប់ផុតយកជ័រធ្វើចន្លុះ
ររនិក្ខាដើមពោងប្លែកយ៉ាងនោះ　　ឱ្យគេចោះចាំងស្រស់ផុតដូច្នេះ ។
ពោងអើយពោងចៅសាងកម្មយ៉ាងណា　　បានជាមកវេទនាឱ្យភ្លើងឆេះ
យើងទៀតមិនដូចឈើពោងនេះ　　បើតាមវិះឈើនេះចុះតម្រា ។
សមណេះមានទ្រព្យសិកាក្លួន　　ស្រីមានខ្លួនប្រុសក្លួនដោយកាមា
ត្រីក្បាជាតិប៉ាប់ប៉ុនព្រោះផ្លែផ្កា　　ត្រីរាំងមានទើបឆ្មាមកយាយី ។
ពោងឯងប៉ាប់ព្រោះមានជ័រទឹកនៅ　　បានជាត្រូវកំដៅព្រះអគ្គី
យើងទៀតឥតជ័រគេរុញស្សី　　គ្មាននរណាយាយីដូចពោងឯង ។
ឱត្រីក្បាត្រូវការមិនថាអ្វី　　កើតសព្រាប់ផែនដីប្រាកដស្តែង
ដូចរូបកាយសង្ខារគេពុំពែង　　មិនផុតការគ្មានឯងពែងអាស្រ័យ ។
ឱត្រីក្បាលទោនាពប្លែក ១　　បុរាណចែកចេះឱ្យឈ្មោះពីរៃ
កោតព្រុំលោកបុរាណចេះកែខៃ　　ឱ្យងាមសព្វពើក្រៃគ្រាន់កំណត់ ។

---

១- សត្វតាវៅ
២- លាន់ឮខ្ទរំពង



www.elibraryofcambodia.org

អនិច្ចាតោថ្មលោកកសាង
ហើយចាថោង « ១ » យ៉ាងរស់ស្មុះប្រែប្រាយ
ឥឡូវមកធ្លាយធ្លាក់បាក់ពាក់ខ្ចាយ
ស្តាយអើយស្តាយមិនគួរបកពិការ ។
បានអ្នកប្រែចម្លែងឥតគំនិត
យៅសំលេវុងកាំបិតគ្រឿងប្រហារ
អោយម្ជុងខ្ទួចខាតតវាច់បង់រសារ
មិនស្តាយការស្នាដៃបុរាណគោរ ។
ឱតោអើយតោយេរមិនមើលទៀង
មកអោយគេសំលៀងខ្លួនតោចុះ
ម្តេចមិនខឹងខាំវាសំលៀងនោះ
អោយវាលុះក្តីមរណ៍យក៏វាទៅ ។
អាណាអើយបំផ្លាញរូបតោលោក
គ្មានប្រយោគអោយយល់ការភក់ជ្រៅ
គួរឬលោកខំសាងតាំងទុកនៅ
មកសត្រូវបំផ្លាញរបស់លោក ។

---

១_ ចាថោង = កាយវិការ ឫកពា

www.elibraryofcambodia.org

# ក្រមាកោលាហល
# ឥតយោបល់ជាតកទី ៥២

មានសត្វទន្សាយមួយ ទៅដេកនៅក្រោមដើមត្នោត ទៀបទីជើងដំបូកមួយ ថ្ងៃនោះមានផ្លែត្នោតមួយទុំ ដល់ពេលក៏ជ្រុះធ្លាក់ចាកទងដល់ដី សព្ទសូរឮព្រោកដោយខ្ទរព្រៃ ។ ឯទន្សាយឮហើយក៏ភិតភ័យ ដោយគិតថាផែនដីស្រុត ទើបស្ទុះក្រោករត់ចេញទៅដោយកម្លាំងផ្អើលពោលពោះផ្លោះទៅដល់សំណាក់នៃគោ ១ ក៏ស្រែកសួរថា មន្សាយអើយចៅរត់ខ្លាំងម្លេះ តើដោយមានការអ្វី ? ទន្សាយប្រាប់ថា « បងគោអើយ ! ផែនដីស្រុតហើយ នៅនេះពុំបានទេ ទៅឱ្យឆាប់ ៗ » ។ គោឮដូច្នោះ ក៏ភិតភ័យស្ទុះពោលទៅជាមុននៃទន្សាយ លុះពោលទៅដល់សំណាក់ជ្រូកក្តាន់១ ក៏ផ្អើលរត់ទៅតាមគោ ១ ពោលទៅដល់សំណាក់ដំរី ១ ឃើញគោពោលមកក៏សួរថា « គោឯងពោលដោយមានការអ្វី ? គោថានៅនេះពុំបានទេ មហាភ័យនឹង កើតមានដល់ពួកយើងហើយ ។ ដំរីឮដូច្នោះហើយក៏ភ័យផ្អើលស្ទុះរត់ទៅជាមុននៃគោ បានទៅដល់សំណាក់ រាជសីហ៍បរមពោធិសត្វជាសត្វប្រកបដោយសតិបញ្ញាកាលបានយល់ ពួកសត្វចតុប្បាទផ្អើលរត់ចលាចល ដូច្នោះក៏សួរទៅដំរីថា ប្រស្នែងដំរី ឯងផ្អើលរត់មកតើព្រោះដំណើរអ្វី ? ។ ដំរីថាខ្ញុំនេះមិនដឹងដំណើរអ្វីទេ ឃើញតែគោពោលក៏រត់តាមគោមក តើព្រោះដំណើរអ្វី ? ។ ដំរីថាខ្ញុំនេះមិនដឹងដំណើរអ្វីទេ ឃើញតែ គោពោលក៏រត់តាមគោមក ដោយឮថាមហាភ័យដល់ហើយ » ។

ពោធិសត្វក៏សួរទៅគោវិញថា « ប្រស្នែងគោឯងនាំគេរត់មកនេះតើដោយហេតុអ្វី ? គោតបថា « ខ្លួនខ្ញុំបាទក៏ពុំដឹងហេតុអ្វី ឃើញតែជ្រូកក្តាន់ផ្អើលរត់ ក៏រត់តាមគេមក » ។ ពោធិសត្វសួរជ្រូកក្តាន់ ១ ក៏ប្រាប់ ថាមិនដឹងដូចគ្នា តែអ្នកដែលផ្តើមនាំរត់នោះ គឺសត្វទន្សាយនេះឯងជាមុនបង្អស់ ។

រាជសីហ៍ពោធិសត្វ ក៏សួរទន្សាយ ១ ប្រាប់ថាខ្ញុំបាទក៏ពុំច្បាស់ហេតុភ័យនោះ មិនដឹងជាសព្ទសូរអ្វីគឺកាលខ្ញុំបាទដេកនៅជើងដំបូក ដែលមានដើមត្នោតមួយដើមដុះនៅខាងកំពុងនិទ្រាលក់ស្រួលស្រាប់តែឮសូរសន្ធឹកអ្វីព្រោកខ្ទោក ខ្ទរផែនដីខ្ទប់ដល់ត្រចៀកខ្ញុំបាទ ១ ភិតភ័យតក្កមាបាក់ដូចជាផែនដីស្រុតព្រោមព្រួន បុកក្រើករំពើកញាប់ញ័រជាប្រាកដហេតុនោះបានជាខ្ញុំបាទរត់ចេញមកនេះ សូមអ្នករាជសីហ៍ជ្រាបហោង » ។



www.elibraryofcambodia.org

ពោធិសត្វឮទន្សាយអធិប្បាយដូច្នោះ ពិចារណាដោយបញ្ញាត្រិះរិះអាការសម្លេងនោះ ក៏ជ្រាបការឥតសង្ស័យទើបប្រស្រ័យទៅថា អ្នកឯងរស់នេះជាសត្វឥតសតិបញ្ញា ហៅថាជាសត្វគំនិតស្រាល កាលឮអ្វីឃើញអ្វី មិនទាន់ច្បាស់នឹងចក្ខុបញ្ញារបស់ខ្លួនក៏គិតស្មានប្រមាណ ហើយភ្ញាក់ផ្អើលភិតភ័យតាមគ្នានាំ ឱ្យលំបាកកាយ អស់កម្លាំងទទេយ៉ាងនេះ យើងគិតទៅយល់ហើយ រឿងសព្ទសូរព្រោកខ្លោកនោះមិនមែនអ្វីទេ គឺផ្លែឈើធ្លាក់ចាកទងនោះឯងជាប្រាកដ ដូច្នេះ ចូរទៅទន្សាយឯងនាំយើងទៅមើលទីនោះ ។ ឯទន្សាយក៏នាំពោធិសត្វទៅត្រង់ទីដើមដំបូកដែលខ្លួនដេកនោះ ពោធិសត្វដើរមើលទីនោះ ក៏បានឃើញ ផ្លែព្នៅមួយយ៉ាងធំ ដែលទើបនឹងជ្រុះមកថ្មី ១ នៅទីនោះទើបប្រាប់អស់សត្វទាំងឡាយមានទន្សាយជាដើមអោយចូលចិត្តថា មហាភ័យដែលកើតដល់អ្នកឯងរាល់គ្នានេះ គឺផ្លែព្នៅមួយនេះឯងយើងរកឃើញហើយ ។ ឯសត្វទាំងឡាយបានដឹងហេតុដើម គឺរាជសីហ៍រកឃើញហើយក៏នាំគ្នាឱ្យសាធុសាធុការ ដល់ពោធិសត្វ ហើយត្មះតិះដៀលខ្លួនឯងដោយឥតសតិបញ្ញានិងពិចារណាការអ្វី ១ គ្រាន់តែឮគេ ឬ ឃើញតែគេផ្អើល មិនសាកសួរហេតុអោយច្បាស់ការនោះជាមុនសិន មិនដឹងថាជាអ្វី ១ ក៏ភិតភ័យផ្អើលឡោឡាចលឡើងនាំអោយខូចកម្លាំងខូចប្រយោជន៍រាត្រីមិទៃ ១ សត្វទាំងឡាយនាំគ្នាសរសើរពោធិសត្វ ហើយក៏លាពោធិសត្វទៅកាន់លំនៅនៃរាត្រីមិទៃ ១ ហោង ។ រឿងនិទាននេះ មានសេចក្តីពិស្តារក្នុងគម្ពីរដីកាបហាសបសូត្រឯណោះ អ្នកប្រាជ្ញគប្បីចូលចិត្តចុះ ។

រឿងនិទាននេះ បានគតិដល់បុគ្គលអ្នកមានគំនិតស្រាល ងាយជឿតែគេ គ្មានគិតគួរពិចារណា ឱ្យដឹងដើមដឹងចុងគ្រាន់តែឮគេក៏បណ្តោយផ្អើលរត់ទៅ បាននូវក្តីក្តៅក្រហាយដូចពួកសត្វចតុប្បាទ ទាំងឡាយផ្អើលតាមទន្សាយនោះឯង អ្នកប្រាជ្ញគប្បីចូលចិត្តទៀតចុះ ។

ទន់ទេរីយទន្សាយ ត្នោតធ្លាក់ជិតកាយ ហាយថាដីស្រុត មិនមើលអោយជាក់ ទៅភ្ញាក់តក់ស្លុតរត់ស្ទើរនឹងផុត អស្វាតបស្វាត ។ ទំពោលទំពោះ ហាក់ដូចគេហោះ នាំសត្វចតុប្បាទ ឱ្យផ្អើលគ្រប់ប្រាណរត់ពានព្រៃស្បាត ពុំនឹងដើររាប ខ្លោចត្នោតវាលេង ។

ដកស្រង់ពីសៀវភៅ គតិលោក ភាគ ៨



www.elibraryofcambodia.org

# ចំបាំងតាកែ
# នៅតំបន់ភ្នំក្រវាញ

នៅសម័យដើម រាជការតម្រូវឱ្យបានការបង់ពន្ធដារពីសំណាក់ប្រជារាស្ត្រ តែក្រោយមករាជការ ផ្លាស់ប្តូរបន្តិច ដោយបើកឱ្យអ្នកស្រុក ដែលជាផលិតករបង់ពន្ធជាមុខទំនិញវិញ ។ នៅតំបន់ភ្នំក្រវាញក៏ បានចេញកងពន្ធសំរាប់យកពន្ធក្រវាញ ដែលគេហៅថា ស្ហួយក្រវាញ ។ រាជការបាត់ដំបងបានតាំង ព្រះវិចិត្រ គិរី ជាភ្នាក់ងារយកពន្ធក្រវាញ ។ រាស្ត្រប្រជាដែលប្រកបរបរបេះក្រវាញនេះគេហៅថា ពួកស្ហួយក្រវាញ។

នៅរវាងឆ្នាំ ១៨៩៨ ពួកស្ហួយក្រវាញ នៅត្រង់សង្កាត់ក្រញូងបានបះបោរប្រឆាំងនឹងការ គាបសង្កត់ សង្កិនឥតត្រាប្រណី ពីសំណាក់ ព្រះវិចិត្តគិរី ដែលជាភ្នាក់ងាររបស់លោកម្ចាស់ ។ ចាស់ៗនៅបាត់ដំបង សុទ្ធតែបានដឹងរឿងការបះបោរនេះ ហើយនិងការបង្ក្រាបយ៉ាងខ្លាំងរបស់រាជធានី សម័យនោះ ។ អ្នកស្រុក បានហៅការបះបោរ និង ការបង្ក្រាបនេះថា ចំបាំងតាកែ ។ លោក **ឧកញ៉ា សុត្តន្តប្រីជាឥន្ទ** បានតែងក្រង ព្រឹត្តិការណ៍ដែលកើតនៅសម័យនោះ ជាកំណាព្យដែលយើងសូម សង្ខេបនិងដកស្រង់ខ្លះ ដូចតទៅ :

នៅរវាងឆ្នាំ ១៨៩៨ ពួកស្ហួយក្រវាញប្រមាណ ៥០០ នាក់ ក្រោមការដឹកនាំរបស់តាកែបាន ក្រោកឡើងបះបោរប្រឆាំងនឹងការសង្កត់សង្កិនយកពន្ធក្រវាញយ៉ាងធ្ងន់ ។ តាកែនេះជាមនុស្សអង់អាច ក្លាហានស្ទាត់ស្ទាញ ហើយខ្លាំងពូកែ « លោកតា ញឹក ប្អូត បាននិយាយតៗតាមចាស់ៗថា តាកែនេះមាន កាយឫទ្ធិលើសគេ ។ តាកែអាចពាំផ្លូងឬស្សីធ្លាយចុះពីដើមដោយយកក្បាលបុកក្រោមពុំបានដោយ ងាយ » ។ តាកែ មានលោកសង្ឃប្អូនប្រុសអង្គឈ្មោះ ប្អូនសៅ ជាបព្វជិត ។ ប្អូនសៅ នេះក៏ពូកែខាង មន្តអាគមវិជ្ជាការរបួសរភាប ស្តោះព្រួស ពាក់សិរិកា ត្រៃភាគបីក ។ ពួកស្ហួយក្រវាញប្រមាណ ៥០០ នាក់ ដោយមានតាកែជាមេដឹកនាំ ក៏បះបោរលែងបង់ពន្ធក្រវាញ ហើយប្រជាប់អាវុធច្បាំងតតាំង នឹងលោក ម្ចាស់ ។ ពួកបះបោរបានដេញកំចាត់ ព្រះវិចិត្តគិរី ពីតំបន់របស់គេ ។ ព្រះវិចិត្តគិរី ក៏យករឿងនេះទៅជំរាប ប្តឹងលោកម្ចាស់ ។



www.elibraryofcambodia.org

លោកម្ចាស់ជ្រាបការហើយក៏និយាយទូវស័ក្ដទៅ ហ្លួងកំភោត ដែលជាចៅហ្វាយស្រុកមោងឫស្សី អោយចាត់ចែងនាំទ័ពទៅបង្ក្រាបនៅតំបន់ភ្នំក្រវាញ ។ ហ្លួងកំភោត ទទួលបញ្ជាតាម ទូវស័ក្ដហើយក៏ចាត់ចែងនាំទ័ពលើកសំដៅទៅតំបន់ភ្នំក្រវាញ ។

ក្រោយពីចេញដំណើរបាន ពីរ បីថ្ងៃ ហ្លួងកំភោត ក៏បោះទ័ពសំរាកនៅបាយរវិល រង់ចាំទ័ពព្រះវិចិត្តគីរី ដែលចេញពីបាត់ដំបងមក ។ នៅពេល ព្រះវិចិត្តគីរី លើកទ័ពទៅដល់ ហ្លួងកំភោត ក៏ជំនុំរកបធ្យោបាយចាប់ តាកែ ។ ហ្លួងកំភោត ក៏សំរេចចាត់ភ្នាក់ងារឱ្យនាំសារទៅល្បួងលោមតាកែអោយចុះចូល ។ វគ្គមួយនៃលិខិតនោះ មានចែងថា :

« ឥឡូវលោកម្ចាស់ប្រើយើងមក ជំរះលៃលកក្នុងរឿងតា
តើតាជាខឹងនឹងអ្នកណា បានជាអហង្ការយ៉ាងនេះហោង ។
ឬខឹងនឹងព្រះវិចិត្ត ដែលតេរីងរឹតទារសួយសង
អោយក្ដៅក្រហាយរស់រាស្ត្រផង បានជាគិតបង្ករអាយ៉ាដក្រោយ » ។

នាយលាញក៏នាំសារចេញទៅ ។ បក្ខពួកតាកែឃើញ ក៏ចាប់អ្នកនាំសារទាំងបីនាក់យកទៅជូន តាកែ ។ តាកែ ក្ដៅណាស់ ក៏ចាត់អោយគេយកនាយលាញ និង មិត្តទាំងពីរទៅសំលាប់ចោល ។ តែគាប់ជួនពេលនោះ ឃុនសៅ បានឃើញ ក៏មកសាកសួរ ហើយសុំបិណ្ឌបាតយកអ្នកទោសទាំងបីយកទៅកន្លែងខ្លួន ។ តែថ្ងៃក្រោយនាយលាញ និង មិត្ត បានបោកប្រាស់ ឃុនសៅ ត្រឡប់មកជំរាបហ្លួងកំភោត អំពីចរិតឥតកែប្រែរបស់ តាកែ ។ ហ្លួងកំភោត ដឹងថាមិនអាចសំរុះសំរួលបាន ក៏ទន្រ្ទាំជើងចាត់សេនា មាហាន ឱ្យប្រុងប្រៀបខ្លួនលើកទ័ពនៅថ្ងៃស្អែកចំរុង

« ទោមចាប់អាកែជាមេក្បត់ សំលាប់អោយម៉ត់ទាំងយោធី
កាប់ក្បាលវាដោតប្រចាំទី អោយក្អែក ត្មាតស៊ីជាភក្សា ។ »

នៅពេលនាំទ័ពចេញទៅ លោករាមសរជិត និង សេនាប្រាក់ ជាមេទ័ពមុខ ។ កងទ័ពត្រូវដើរតាមផ្លូវតូចចង្អៀតក្បែរមាត់ជ្រោះ ។

ពួកល្បាតខាង តាកែ ឃើញទ័ព ហ្លួងកំភោត ហើយ ក៏បាញ់កាំភ្លើងជាសញ្ញាដល់បក្ខពួកខ្លួន ។ តាកែ ក៏នាំទ័ពចេញមកភ្លាមដែរ ហើយបាញ់គ្នាទៅវិញទៅមកយ៉ាងកោលាហល ។ បន្ទាប់មក តាកែ


www.elibraryofcambodia.org

ទាញដាវដេញកាប់ពលទាហានសេនាប្រាក់ ហើយប្រយុទ្ធគ្នាដាវ និង ដាវ ជាមួយសេនាប្រាក់ ដែល

លោក **សុត្តន្តប្រីជាឥន្ទ** បានចងជាកំណាព្យថា ៖

« អាកែលោតចាក់អាប្រាក់ចាប់ អាកែបែរកាប់អាប្រាក់គេច
ស្ទុះរត់បាកវិលដូចគេវិច ពលបែកថយគេចរត់បរា ។
អាកែមានជ័យដេញកាប់ចាក់ ពួកទ័ពអាប្រាក់រត់ផ្អើលផ្លា
រត់ជ្រួលប្រពាក់ប្រពួនគ្នា ខ្លះដួលខ្លះពារវារពួនជ្រក ។
ខ្លះស្ទួន់រត់ពួនប៉ះដើមឈើ ទល់ផ្អកងើងើដូចគេបាក
អាកែដេញដល់កាត់ក្បាលយក នាំមកដោតឆ្កាងខាងផ្លូវថ្លា ។
អាផាក់អាក្រាយដេញប្រឈម កាប់ដៃអាអោមដាច់ពីស្មា
អាអោមរត់ប៉ះជាន់សិលា ដួលផ្ងារលើព្រៃក្ស័យជីវិត » ។

ឃើញទ័ពសេនាប្រាក់ដកថយហើយ ពាកែ ក៏ប្រមូលគ្នាអោយត្រឡប់ក្រោយវិញ ។ ទ័ពខាងហ្លួងកំភោគ ភ័យស្លន់ស្លោររត់ប្រសេចប្រសាចទៅប្ដឹងហ្លួងកំភោគ ។ ក៏ភ័យភាំងទៀតបង្កើតជាវិការដ្ឋានមួយគួរឱ្យអស់សំណើចដូចមានកំណាព្យថា ៖

« ឯភាមតេជោជាទ័ពណ្ឌួន ឃើញក្បួនទ័ពបែកទៅទីទៃ
ស្រែកប្រាប់ទៅថាបរាជ័យ ចាញ់ដៃអាកែវាដេញហើយ ។
ទ័ពភាមតេជោភាមសរជិត ភ័យភិតមិនរត់មិនមើលឡើយ
ខ្លះស្រែកថាឆាប់វាកាប់ហើយ ខ្លះសឿយកំលាំងតាំងបាមា ។
ខ្លះធ្លាក់អាវុធរំពីដៃ អ្នកខ្លះធ្លាក់ទៃរំពីស្មា
ខ្លះធ្លាក់ខ្នុកត្រពីកេសា ខ្លះរបេខ្លះរបាមាត់រត់ទៅ ។
ថ្លែងពីអាយ៉ោកបាវឃុនហ្លួង ឃើញទ័ពទាំងពួងបែកខ្លួលខ្មៅ
ទើបស្ទុះរត់ចេញមកខាងក្រៅ ចូលទៅប្ដឹងហ្លួងកំភោគ ថា ។
លោកនាយអញ្ជើញរត់អោយឆាប់ អាកែដេញកាប់មកហើយណា
ឃុនហ្លួងឮហើយរត់ផ្អើលផ្លា ថាមែនឬអា - ឯណាទ័ព ។
អាយ៉ោកថាហ្នឹងនោះលោកនាយ ពលយើងរត់រាយបែកក្រឡាប់


www.elibraryofcambodia.org

យុនហ្លួងថាធ្មោះឯងឆាប់ៗ
ទៅចាប់យកសេះមកអោយអញ ។
ឯម៉ឺនហ្លួងផុនឃុំស្បៀងចែក
ឮថាម៉ឺនបែករាកែដេញ
ភិតភ័យស្លន់ស្លុតរត់ពាសពេញ
ខ្លះដេញគោមកបិះបរបេះ ។
ខ្លះស្លន់បឺមគោយកក្បាលធ្លុះ
រាគោកញ្ច្រោលដោយបរបេះ
ខ្លះចាប់ច្រម្បីយកឯសេះ
មកបិះបរបេះថាជាគោ ។
ខ្លះបឺមគោពីរបេះពីរ
ឡើងបររកវិវាទយពាយោ
ដល់នឹមធ្លាក់ង៉ែតស្រែកពុទ្ធោ
ស្ទុះដោះគោបឺមសារជាថ្មី ។
ខ្លះបីបកណ្ដាលខ្លួនគោភ្លាម
ដល់ដាក់ខ្សែទាមថាខ្សែតី
ខ្លះស្លន់រត់ព័ន្ធគោក្របី
ខ្លះចាប់ដីរីថាទៃត្រូ ។
ខ្លះស្លន់រត់ជាន់ហិបប្រវប់
ដួលចុះកំពប់ធ្លាក់ស្បាថ្នូរ
ខ្លះប៉ះដើមឈើធ្វើមុខជួរ
ខ្លះរកគុណគ្រូឪពុកម្ដាយ ។
ខ្លះដួលរាក្រាតស្រាតចេញក្រៅ
កន្ត្រាក់យករាវមកបិទកាយ
ខ្លះរត់ប៉ះព័ន្ធនាយទៅហ្វាយ
នាយព្រាយបាវប្រាសគាស់ដៃគ្នា ។
នាយដួលបាវដេកពៅពើខ្នង
នាយធ្លាក់បាវផងគេចពានពារ
នាយទះបាវតប់ប្រសប់គ្នា
ស្ទុះពារប្រពួនល្បួនរត់ទៅ ។
ឯហ្លួងកំភោតលោតឡើងលើសេះ
ក្រោយគិតថាអេះឈប់សិននៅ
ចាំមើលឱ្យដឹងកិច្ចភាក់ប្រជៅ
នឹងទៅក្រែងពលផ្ដើលខ្លាត់ខ្លាយ ។ »

នៅពេលនោះលោកវិសេសប៉ោកន ឆ្នូវ ដែលបាក់ម៉ឺតដែរនោះ មិនព្រមទៅជួបហ្លួងកំភោតទេ ព្រោះ « ខ្លាចព្រៃទៀតចង្អៀតចិត្ត » ។ គាត់ក៏បកស្រុកបាត់ដំបង ដេកពុតធ្វើជាគ្រុនចាញ់ស្រុកលើ ។ ហ្លួងកំភោត ក្ដៅក្រហាយនឹងបរាជ័យរបស់ម៉ឺតខ្លួន ក៏ដាច់ចិត្តបកសំបុត្រប្ដឹងដល់លោកម្ចាស់ ដើម្បីសុំរ៉េតជំនួយ ។ ហ្លួងកំភោតក៏ចាត់នាយវេននាំសំបុត្រទៅជូនលោកម្ចាស់នៅឯកំផែង ។ ដោយនៅពេលនោះ លោកម្ចាស់ពិននៅក្នុងកំផែង លោកម្ចាស់នៅឯភាគ នាយវេនក៏ឡើងសេះបន្តដំណើរទៅភាគទៀត ។ លោក **ឧកញ៉ាសុភក្តិប្រីជាឥន្ទ** បានពិពណ៌នាវិធីចំនៀបលោកម្ចាស់នៅភាគថា៖



www.elibraryofcambodia.org

« ដល់ហើយដល់ភាសមិទំនៀម | ទៅប្អូនលោករៀបរាប់ជាមិភាក់
មានស្នែងខ្វាត់ខ្វែងតែងច្រើនថ្នាក់ | ចុនក្រោយលោយចក្រសឹងជាលេខ ។
ជញ្ជាំងចង្អួចសឹងស្លឹករឹត | ឫស្សីវិចិត្តជាជើងខ្វែក
ខ្លះជាដកចង្ហូកាន់ញុងបែក | មើលឯកលើសរស់មិមានា ។
បន្ទប់ស្រលស្រស់អស់ទឹកលិច | ពោកនៅជានិច្ចដូចបុប្ផា
មានឈើដុះជាំងស្ងួនហោ | វាតាំរតើកស្ទើរក្តីក្តៅ ។
ស្ពានវាលព្រៃវែងតាកដួរស្ទឹង | ទឹកមិនងឹងគ្មានហូរធ្លាយរំហែងពៅ
មច្ឆារាស្រីយជាលំនៅ | ត្រង់ជ្រៅត្រីជ្រកច្រើនក្រាស់ក្រៃ ។
ខាងលើធ្វើស្ពានជាស្ពានធ្លង | រស់វាត្រូវលេសផងបានរាត្រីវែក
ដើរឆ្លងទៅមកទាំងយប់ថ្ងៃ | ក្មេងចក្រុងឥតភ័យផងពារធា ។ »

លោកម្ចាស់បានទទួលសំបុត្រពីនាយវេន ចើររៀបទៅដឹងរំពឹបរាជ័យរបស់ពីត ឬដូចកំភោគ ក៏ណាន់មាត់ថា :

« គួរឬធ្វើការបរាជ័យ | អោយអារអ្នកក្រៃកើលងាយបាម
ឡាវានោះតើមានប៉ុន្មាន | បានជាមិនហ៊ានចូលហ្លួងនា ។
បង់ជាតិកំណើតកើតជាប្រុស | ធ្វើអោយរាប់លេសប្រុសដូចគ្នា
ចិត្តតូចប៉ុណ្ណេះបកគេថា | ចំណង់ប្រើជាចិត្តធំដុំ ។
ទៅលេងនឹងគេឯណាបាន | សមរម្យរបានទាំងតូចធំ
តែចិត្តវាក្រៃរត់កន្ធំ | មកនៅសាំងំពារវិរៈ ។ »

លោកម្ចាស់ប្រាប់នាយវេន អោយត្រឡប់មកវិញចាំពីរ បីថ្ងៃទៀតលោកនឹងគាត់ការ ។ ក្រោយនោះលោកម្ចាស់ក៏វិលមកកាន់កំផែងវិញ ហើយបោកស្មៀនព្រះអោយវាយទូរលេខទៅខាងកក ស្តីរារុកពីរដ្ឋាភិបាលសៀម ។ កំណាព្យមានប្រាជ្ញកតទៅ :

« ស្មៀនព្រាមទូរព្រមតភាគជ័ផ្ទាត់ | លើកបត្តលោផលពួកកៀវការ
ទៅដល់រោងលួសហើយទិកហោ | និងនាយពីស្សុីរធ្យាត្រូវរាំ ។
ថាលោកជាម្ចាស់មានការក្តៅ | សួរវាយលួសទៅឯក្រុងក្រៃ
ចំពោះក្រសួងក្រុមមហាផ្ទៃ | អញ្ជើញនាយវីឥឡូវណេក ។



www.elibraryofcambodia.org

ថាហើយស្មៀនត្រាកត់ពាក្យប្រាប់ ជាអក្សរស័ព្ទតាមភាសា
បិស្តិ ទទួលប្លូលមេរឿកា ខារស្មេរអីង១ អីងដល់ហោង ។ »

ព្រះតៅសៀវមទទួលដំណឹងហើយ ក៏យល់ព្រមតាមសុំ ។ លោកម្ចាស់ទទួលទូរលេខពីបាងកក ហើយ ក៏តាប់រះមេះឱ្យទៅដឹកកាំភ្លើងធុនថ្មីយ៉ាងចំនើប គឺកាំភ្លើងមីលីយើថិចំនួន ១០០ ដើម ពីសិរីសោភ័ណ ។ លុះបានអាវុធថ្មីនេះហើយ លោកម្ចាស់ក៏ចាត់ការឱ្យរៀបចំទ័ពទៅបង្ក្រាប តាកែ ឯភ្នំក្រវាញ ។ កងទ័ពត្មើរជើង ម៉ែតសេះ រទេះ និង ដំរី ចេញដំណើរកាត់តាមភូមិស្ទឹង ភូមិបឹងក្រសាល រួចទៅ ដល់ភូមិ កញ្ចាំង ពោះប៉ែតនៅទីនោះ ។ ក្រោយមកលោកម្ចាស់ចាត់ចំបែកទ័ពជាបីផ្នែក មួយផ្នែកទៅតាមផ្លូវ រមាំង មួយផ្នែកទៅតាមកំពង់រពៅ និងមួយផ្នែកទៀតទៅតាមភូមិត្រដោក ។ ពលទាហានសុទ្ធតែមានធង កំណាត់ពណ៌ក្រហម ស ខ្មៅ ទៅតាមកងជាសញ្ញា ។

តាំងពីពេលបាក់ទ័ពមក ព្រះវិចិត្តគិរីពួនក្នុងព្រៃជានិច្ច ។ ទើបតែពេលនេះ ដាច់ចិត្តចេញមកសុំទោស លោកម្ចាស់ ១បានស្តីបន្ទោសដូចពោលកំណាព្យថា :

« បន្ទោសតែព្រះវិចិត្ត គំនិតសោតដូចស្រីសំផឹង
បានតែរាណោកគ្នានឹង ១ គ្មានលោះមួយស្នឹងអំពីគ្នា ។
មេរុះហៅទះដៃយ៉ាងតាកែ ភ្លេកសលេក់ចិះរបស់វា
ប្លើះមិនខ្មាសគេផងមានា នៅរួតថាជាមេកងស្នូយ ។
បានស៊ី ១ កិនរើសមុខ បានទុក ១ មករកគេជួយ
ប្រើមកគ្មានបានការផ្ទួចមួយ អោយពួករាស្ត្រយមាក់ងាយបាន ។ »

លោកម្ចាស់បញ្ជាទ័ពអោយលើកទៅបោះទៅខាងមុខទៀត ។ នៅពេលយប់មានកូឡាម្នាក់ចូលមកសុំយកសាតការលោកម្ចាស់ទៅយកក្បាលតាកែ ដោយសុំឱ្យលោកម្ចាស់អនុគ្រោះឱ្យខ្លួនបានរៀបការជាមួយកូនក្រមុំ ពាដារ៉ា ដែលជាបក្ខពួក តាកែ ។ លោកម្ចាស់មានការសង្ស័យក៏បដិសេធពាក្យសុំរបស់កូឡានេះ ។ តាមពិតកូឡានេះជាភ្នាក់ងាររបស់ តាកែ មែន ។ កូឡានេះ ចូលមកស៊ើបការណ៍ពីស្ថានភាពទ័ពលោកម្ចាស់ទៅប្រាប់ តាកែ ។

តាកែបានប្រមូលបក្ខពួក ហើយបាញ់កាំភ្លើងយកជ័យ ។ យួន សៅ ក៏សេពមន្តវិជ្ជាការពារគមតាថា ការពារពលទាហាន ។ តាកែចាត់គ្នាប្រាំនាក់ឱ្យមកព័ទ្ធច្រកចូលទៅកាន់ភូមិ ។



www.elibraryofcambodia.org

ព្រឹកស្អែកឡើង លោកម្ចាស់ដាស់ពលទាហានឱ្យដាំបាយហើយចេញដំណើរទៅ ។ លុះដល់ផ្លូវចូលទៅភូមិអង្គជុំ ពួកល្បាតតាកែក៏នាំដំណឹងទៅប្រាប់មេកើយខ្លួន ។ តាកែដឹងហើយក៏បញ្ជាវាយ ពលទាហានបាញ់ពលលោកម្ចាស់ដោយឥតសំចៃដៃ ។ ពួកខាងលោកម្ចាស់បាញ់ តាកែ ដួលធ្លាក់ ។ តាកែ ស្ទុះក្រោកតដៃទៀត តែទ្រាំមិនបានក៏ដួលដេកស្លាប់ទៅ ។ ពួកពលតាកែក៏ស្លាប់ដេរដាស ហើយខ្លះក៏រត់យករួចខ្លួនទៅពួនក្នុងព្រៃ ។

នៅពេលនោះ សេនាប្រាក់ក៏នាំពួកពលរត់ចូលទៅរកលោកសង្ឃឡូង ។ ដែលនៅឯភូមិតាប្រាក់ ចូលទៅចាប់ ឡូង សៅ ចេញមកក្រៅ ។ លោកសង្ឃឡូងនេះអង្វរតាប្រាក់ថាសុំឆាន់បាយសិន តែតាប្រាក់មិនសុខចិត្ត ក៏បណ្តោយឱ្យកើតមានការវាយតប់គ្នាយ៉ាងខ្លាំងដូចមានចែងជាកំណាព្យថា ៖

« តាប្រាក់ឃើញឡោះស្ទុះចូលទៅ　　　ថាពះវានៅបីនោះណោ ។

នៅទីបញ្ចប់លោក **ឧកញ៉ាសុត្តន្តប្រីជាឥន្ទ** បានសរសើរវីរភាពរបស់តាកែដូចមានឃ្លាថា ៖

« តាកែបើមើលតាមដំណើរ　　　គួរគេសរសើរចិត្តវាជា
គួរឬកាំភ្លើងយើងបាញ់វា　　　ត្រាប់ជាលោជផ្ទុះហ៊ានស្ទុះយុទ្ធ ។
ត្រូវដួលចុះប្រឹងក្រោកត្រដរ　　　ដៃច្បាំងបាញ់តទាល់ដៃផុត
ចិត្តរឹងមានះគ្មានរន្ធត់　　　ឥតស្លុតក្តីស្លាប់វិនាសប្រាណ ។
អើនេះសមពេញជាមេទ័ព　　　គួររាប់ហៅថាជាទាហាន
មនុស្សយ៉ាងនេះកម្របាន　　　ច្រើនតែមៅពានកំសាកញី ។ »

លោកម្ចាស់ ចាត់ចែងឱ្យគេត្រួតពិនិត្យទ្រព្យសម្បត្តិរបស់ តាកែ និង បក្សពួកប្រមូលយកមកដាក់ឃ្លាំង ។ គេយកក្បាលតាកែ និង យកមកដោតនៅដើមផ្លូវ ។

តុល្យការនៃការប្រយុទ្ធនេះ គឺខាងតាកែមានស្លាប់ ២៦ នាក់ ឯខាងលោកម្ចាស់មានស្លាប់តែពីរនាក់ទេ ។

យើងមិនអាចដឹងអំពីជំរៀតជំរែកពីខាងក្រៅក្នុងរឿងបះបោរនេះទេ តែគួរឆ្ងល់ពីវត្តមាននៃ ឡូង សៅ នៅក្នុងទីនេះ ។ ឬមួយក៏ជាភាំងចកបង្ករឿងនៅទីនេះ ?

www.elibraryofcambodia.org

# « នឹកមិនភ្លេច »

• លោកគុរុគុណ　ប្រើជាឥន្ទ　ប៉ិនប្រសប់
ប្រមូលគ្រាប់　ពូជពាក្យខ្មែរ　ថែមុកនៅ
បណ្តុះក្រិត្យ　ប្រឌិតគ្រឿង　រឿងប្រដៅ
ដល់កូនចៅ　ជំនាន់ក្រោយ　ឱ្យចងចាំ ។

• ទឹកខ្មៅស្រក់　ដក់លើខឿន　អក្សរសាស្ត្រ
ផ្កាស្រឡះ　ជះពន្លឺ　ភ្លឺរយឆ្នាំ
គតិលោក　ប៉ងនាំខ្មែរ　កុំប្រែស្រាំ
បែកឆ្វេងស្តាំ　ត្រូវមិត្តចំ　សាមគ្គីគ្នា ។

• មួយជីវិត　ពិតជាមាន　តម្លៃខ្ពស់
ស្លាប់ដូចរស់　ឈ្មោះថិតនៅ　ជាប់កម្ពុជា
ស្ងួបព្រលឹង　លោកទៅសោយ　សុខសួគ៌ា
យើងគ្រប់គ្នា　ចាំមាហា　លោកជានិច្ច ។

• កូនចៅដោះ　ផ្អែមមធុរស　ទោះយ៉ាងណា
ដូចខេមរា　បានរានហើយ　ចាំមិនភ្លេច
ស្នាដៃលោក　ផ្អែមហើយថ្លៃ　ជាងដុំពេជ្រ
នឹកមិនភ្លេច　គុណទឹកខ្មៅ　កវីខ្មែរ ។

គ.ប.ឈ



www.elibraryofcambodia.org

- ទទួលខុសត្រូវបោះពុម្ព : លោក គង្គ ប៊ុនឈឿន
- រៀបរៀង : លោក ទ្រាំ សំអ៊ាន
- កែ អក្ខរាវិរុទ្ធ : លោក ឱក សារុន
លោកស្រី ម៉ាយ សុគន្ធា
- ខ្នាត : ១២ x ២០
- បោះពុម្ពនៅរោងពុម្ព : ណុប បូផាន់
- ចំនួន : ១.០០០ ក្បាល
- បោះពុម្ពចប់នៅថ្ងៃទី : ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៤
- តម្កល់ទុកជាឯកសារ : ខែ ធ្នូ ឆ្នាំ ១៩៩៤

**បោះពុម្ពលើកទី ១**

**ឆ្នាំ ១៩៩៤**

www.elibraryofcambodia.org

ID : 4845 Shelf mark : Le/920/KON/1

បណ្ណាល័យជាតិកម្ពុជា
National Library of Cambodia

| ថ្ងៃ ខែ ឆ្នាំ | ថ្ងៃ ខែ ឆ្នាំ |
|---|---|
| Date of Return | Date of Return |
| 21 JUN 2007 | |

www.elibraryofcambodia.org

បោះពុម្ពផ្សាយដោយ
នាយកដ្ឋានបោះពុម្ពផ្សាយ វប្បធម៌
នៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

0693 006056 08200693

www.elibraryofcambodia.org